KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

# សេចក្តីប្រកាសព័ត៌មាន

## ជំនួបសម្តែងការគួរសមរបស់**លោក ប៊ែរត្រង់ ល័រតូឡារី** ប្រធាននាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងអឺរ៉ុប និងការបរទេសនៃសាធារណរដ្ឋបារាំង ចំពោះ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង លទ្ធផលនៃសម័យប្រជុំលើកទី១នៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីកម្ពុជា-បារាំង

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២៣

* * * * *

នៅព្រឹកថ្ងៃច័ន្ទ ទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ **លោក ប៊ែរត្រង់ ល័រតូឡារី** ប្រធាននាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងអឺរ៉ុប និងការបរទេសនៃសាធារណរដ្ឋបារាំង បានចូលជួបសម្តែងការគួរសមចំពោះ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា មុននឹងចាប់ផ្តើមកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីកម្ពុជា-បារាំងលើកទី១ ជាមួយ **ឯកឧត្តមបណ្ឌិត ចែម វីឌ្យ៉ា** រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃដដែល បន្ទាប់ពីសេចក្តីប្រកាសគោលបំណងរួមស្តីពីការបង្កើតយន្តការនៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីរវាងកម្ពុជា និងបារាំង ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣។

**ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរចំពោះចំណងមិត្តភាពដ៏យូរលង់ដែលផ្សារភ្ជាប់កម្ពុជា និងបារាំង។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចការងារនាពេលថ្មីៗនេះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងប៉ារីស កាលពីថ្ងៃទី១៣ ខែធ្នូ កន្លងទៅ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបង្ហាញសេចក្តីសោមនស្សចំពោះដំណើរទស្សនកិច្ចនាពេលថ្មីៗនេះរបស់លោក **អូលីវីយេរ ប៊ិច** រដ្ឋមន្ត្រីប្រតិភូអមរដ្ឋមន្ត្រី នៃក្រសួងអឺរ៉ុប និងការបរទេសបារាំង ទទួលបន្ទុកពាណិជ្ជកម្មក្រៅប្រទេស ការទាក់ទាញ និងជនជាតិបារាំងរស់នៅបរទេស ។ ព្រឹត្តិការណ៍ទាំងពីរនេះ បានពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការនយោបាយ និងសេដ្ឋកិច្ច រវាងប្រទេសកម្ពុជា និងបារាំង។



Address : Nº 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនលោកប្រធាននាយកដ្ឋាន អំពីភាពជោគជ័យរបស់កម្ពុជាក្នុងការធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញរបស់កម្ពុជាក្នុងកាជម្រុញឲ្យអនុវត្តនូវកិច្ចព្រមព្រៀងជាឯកច្ឆ័ន្ទប្រាំចំណុចស្តីពីមីយ៉ាន់ម៉ា និងនាំប្រទេសនេះត្រឡប់មករកស្ថានភាពជាប្រក្រតីវិញតាមរយៈកិច្ចសន្ទនា។

**លោក ប៊ែរត្រង់ ល័រតូឡារី** បានវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យដ៏ធំធេងរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ចាប់តាំងពីដំណើរទស្សនកិច្ចរបស់លោកនៅកម្ពុជាលើកដំបូងរបស់លោកនៅឆ្នាំ១៩៩៣ ដែលកាលនោះលោកជានិស្សិតនៅឡើយ ។ លោក ក៏បានអបអរសាទរយ៉ាងកក់ក្តៅចំពោះការធ្វើជាប្រធានអាស៊ានរបស់កម្ពុជានៅឆ្នាំ២០២២ ជាពិសេសក្នុងបរិបទនៃការគ្រប់គ្រងវិបត្តិដែលកំពុងកើតមាននៅក្នុងតំបន់ និងជុំវិញពិភពលោក ដូចជានៅប្រទេសមីយ៉ាន់ម៉ា ដែលកម្ពុជាបានដាក់ចេញនូវសកម្មភាពឥតឈប់ឈរជាច្រើន ក្នុងគោលដៅជួយអនុវត្តនូវកិច្ចព្រមព្រៀងជាឯកច្ឆ័ន្ទប្រាំចំណុចដែលទទួលបានការឯកភាពពីប្រមុខរដ្ឋ/រដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន ដើម្បីជួយដោះស្រាយភាពតានតឹងនានា ក្នុងរយៈពេលពេញមួយឆ្នាំ ២០២២កន្លងទៅនេះ។

នៅឆ្នាំ ២០២៣ នឹងមានការប្រារព្ធខួបលើកទី ៧០ នៃបុណ្យឯករាជ្យជាតិកម្ពុជា ការបង្កើតវិទ្យាស្ថានប៉ាស្ទ័រ និងជាខួបលើកទី ៣០ នៃ CIC អង្គរ ព្រមទាំងវត្តមានរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនៅកម្ពុជា។

នាថ្ងៃដដែល **ឯកឧត្តមបណ្ឌិត ថែម រីឌ្យ៉ា** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំសម័យប្រជុំលើកទី១នៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីរវាងកម្ពុជា និងបារាំងជាមួយលោក **ប៊ែរត្រង់ ល័រតូឡារី** ប្រធាននាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងអឺរ៉ុប និងការបរទេសនៃសាធារណរដ្ឋបារាំង។

ភាគីទាំងពីរ បានចែករំលែកពីស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គម នៃប្រទេសរៀងខ្លួន ក្នុងស្មារតីយល់ច្បាស់ពីនីតិរដ្ឋ ដែលគ្រប់គ្រងប្រទេសរៀងខ្លួន។ ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈស៊ីជម្រៅលើទំនាក់ទំនងទ្វេភាគីលើវិស័យនយោបាយ សេដ្ឋកិច្ច អប់រំ និងវប្បធម៌។ ភាគីទាំងពីរ បានព្រមព្រៀងគ្នាក្នុងការពង្រីកបន្ថែមទៀតនូវទំនាក់ទំនងពាណិជ្ជកម្ម និងជំរុញការវិនិយោគ តាមរយៈភាពទាក់ទាញរបស់កម្ពុជា នៅក្នុងទីផ្សារប្រកបដោយថាមវន្តក្នុងសហគមន៍អាស៊ាន និងនៅក្នុងតំបន់ដ៏ធំធេងនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP) ព្រមទាំងតាមរយៈអត្តសញ្ញាណពីរនៃការប្រើប្រាស់ភាសាបារាំងផង និងភាសាអង់គ្លេសផង ក៏ដូចជាច្បាប់វិនិយោគថ្មីនៅកម្ពុជា និងលក្ខណៈភូមិសាស្ត្រអំណោយផលរបស់កម្ពុជានៅចំកណ្តាល អាស៊ាន។ ទន្ទឹមនេះ ភាគីបារាំង បានកត់សម្គាល់ពីយុទ្ធសាស្ត្រថ្មីរបស់រាជរដ្ឋាភិបាលក្នុងការផ្តោតលើកិច្ចសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសាស្ត្រសម្រាប់អនាគត និងលើការបណ្តុះបណ្តាលធនធានមនុស្សមានវិជ្ជាជីវៈត្រឹមត្រូវ ដល់យុវជនសរុបចំនួន ១,៥ លាននាក់ ក្នុងឆ្នាំខាងមុខ

ដើម្បីអមដំណើរយុទ្ធសាស្ត្រថ្មីខាងលើនេះបានជោគជ័យ។ បារាំង ជាប្រទេសមានជំនាញច្បាស់លាស់ដ៏ប្រណិតក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងន័យនេះ លោក **លោក ប៊ែរត្រង់ ល័រតូឡារី** បានកោតសរសើរចំពោះជោគជ័យដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលក្នុងយុទ្ធសាស្ត្រលុបបំបាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យសេដ្ឋកិច្ចមានការងើបឡើងវិញយ៉ាងឆាប់រហ័ស ប្រកបដោយថាមវន្ត និងគួរឱ្យកត់សម្គាល់ក្នុងរង្វង់ ៥,២% ក្នុងឆ្នាំ ២០២២។

ដោយឡែក **ឯកឧត្តមបណ្ឌិត ចែម វីឌ្យ៉ា** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃចំណងមិត្តភាពស្មោះត្រង់ដ៏យូរអង្វែង ដែលកម្ពុជា ថែរក្សាជាមួយបារាំង រួមមានក្នុងក្របខណ្ឌហ្វ្រង់កូហ្វូនីដែលកម្ពុជាជាប្រទេសសមាជិកស្ថាបនិក តាមគំនិតផ្តួចផ្តើមនៃអង្គ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនៈកោដ្ឋ** ព្រះប្រមុខរដ្ឋកម្ពុជាកាលពីដើមឆ្នាំ ១៩៧០។ កម្ពុជា ក៏បានអបអរសាទរចំពោះតួនាទីនាំមុខរបស់បារាំងចំពោះសន្តិភាព ការស្តារឡើងវិញ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ ទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវត្តមានជាប្រចាំដ៏យូរលង់របស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនៅទីនេះ។

លើសពីនេះ ភាគីទាំងពីរ បានឯកភាពគ្នាពីសារៈសំខាន់យ៉ាងខ្លាំងនៃទំនាក់ទំនងអាស៊ាន-បារាំង រួមមានការបន្តចរចារលើតំបន់ពាណិជ្ជកម្មសេរី ពីតំបន់មួយទៅតំបន់មួយ រវាងអាស៊ាន និងសហភាពអឺរ៉ុប។ កម្ពុជា វាយតម្លៃខ្ពស់ចំពោះយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់សហភាពអឺរ៉ុប តាមរយៈវេទិកាថ្នាក់រដ្ឋមន្ត្រីសម្រាប់កិច្ចសហប្រតិបត្តិការឥណ្ឌូប៉ាស៊ីហ្វិក ដែលបានធ្វើឡើងក្រោមអធិបតីភាពបារាំងជាប្រធាន គណៈកម្មាការអឺរ៉ុប នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០២២ នៅទីក្រុងប៉ារីស។ យុទ្ធសាស្ត្រនេះ បំពេញបន្ថែមលើយុទ្ធសាស្ត្រអាស៊ាន តាមរយៈទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក។

កម្ពុជា និងបារាំង គាំទ្រលើការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះច្បាប់អន្តរជាតិ និងពហុភាគីនិយមតាមរយៈស្ថាប័នអន្តរជាតិនានា ជាពិសេសដូចជា អង្គការសហប្រជាជាតិ អាស៊ាន និងសហភាពអឺរ៉ុប។

តំណាងក្រសួងការបរទេសទាំងពីរ ក៏បានគូសបញ្ជាក់ផងដែរអំពីបច្ចុប្បន្នភាពដ៏លេចធ្លោស្តីពីការដោះស្រាយបញ្ហាប្រឈមរួមគ្នាជាសាកល រួមមានការប្រែប្រួលអាកាសធាតុ និងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ព្រមទាំងបញ្ហាប្រឈមនានាដែលមិនមែនជាប្រពៃណី តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីព្យាយាមដោះស្រាយជម្លោះក្នុងតំបន់ ដោយប្រើប្រាស់មធ្យោបាយសន្តិវិធី និងកិច្ចសន្ទនាប្រកបដោយបរិយាប័ន្ន។

សម័យប្រជុំលើកទី១នៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីរវាងកម្ពុជា និងបារាំង បានប្រព្រឹត្តទៅក្នុងបរិយាកាសមិត្តភាពស្និទ្ធស្នាល ប្រកបដោយការគោរពគ្នា និងទំនុកចិត្តទៅវិញទៅមក។

សម័យប្រជុំលើកទី២ នៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរ នឹងប្រព្រឹត្តទៅនៅឆ្នាំក្រោយ នៅទីក្រុងប៉ារីស៕

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២៣